**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០៧ សរ

# សារាចរ

## ស្តីពី

## ការហាមប្រជាពលរដ្ឋខ្មែរមិនឲ្យលក់ ឬជួលដីស្រែ ដីចំការ ឬដីលំនៅឋាន នៅតាមតំបន់ព្រំដែន ឲ្យទៅប្រជាពលរដ្ឋនៃប្រទេសជិតខាង

នាពេលកន្លងមកនេះ មានប្រជាពលរដ្ឋខ្មែរមួយចំនួនបានជួលដីស្រែ ដីចំការ ឬដីលំនៅឋានរបស់ខ្លួន នៅតាមតំបន់ព្រំដែន ឲ្យទៅប្រជាពលរដ្ឋនៃប្រទេសជិតខាងដូចជា វៀតណាម ឡាវ និងថៃ ដើម្បីបង្កបង្កើនផល ដាំដុះដំណាំ ឬប្រកបអាជីវកម្មផ្សេងៗ។ល។ ការជួលដីរបស់ប្រជាពលរដ្ឋខ្មែរទាំងនេះមានករណីខ្លះពុំមានរៀបចំឯកសារគតិយុត្ត ឬកិច្ចសន្យាជួលឲ្យបានត្រឹមត្រូវតាមផ្លូវច្បាប់ឡើយ ដែលជាហេតុធ្វើឲ្យម្ចាស់ដីជាជនជាតិខ្មែរបាត់បង់នូវផលប្រយោជន៍ នៅពេលមានវិវាទកើតមានឡើង។ ម៉្យាងវិញទៀត នៅតំបន់ព្រំដែនដែលពុំទាន់បានកំណត់ខណ្ឌសីមា និងបោះបង្គោលព្រំដែនផ្លូវការរួចរាល់ជាស្ថាពរ ការជួលដីនៅតាមខ្សែបន្ទាត់ព្រំដែនរបស់ប្រជាពលរដ្ឋខ្មែរទៅឲ្យប្រជាពលរដ្ឋនៃប្រទេសជិតខាង បានបង្កឲ្យមានភាពស្មុគស្មាញដល់កិច្ចការរបស់គណៈកម្មាធិការចំរុះកិច្ចការព្រំដែនក្នុងការអនុវត្តការងាររបស់ខ្លួន។

ដើម្បីរក្សាការពារនូវសិទ្ធិកាន់កាប់ដីធ្លី និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋខ្មែរ ក៏ដូចជាការជួយជំរុញ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមតំបន់ព្រំដែន ព្រមទាំងជួយសម្រួលដល់ការងារកំណត់ខណ្ឌសីមា និងបោះបង្គោលព្រំដែនជាមួយប្រទេសជិតខាង សំដៅរក្សាការពារឲ្យបាននូវបូរណភាពទឹកដី និងអធិបតេយ្យភាពជាតិ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការដូចខាងក្រោម៖

១- ហាមប្រជាពលរដ្ឋខ្មែរមិនឲ្យលក់ ឬជួលដីស្រែ ដីចំការ ឬដីលំនៅឋាននៅតាមតំបន់ព្រំដែនឲ្យទៅប្រជាពលរដ្ឋនៃប្រទេសជិតខាង ទោះបីក្នុងរូបភាពណាក៏ដោយ។

២- ក្នុងករណីដែលមានការជួលដីរួចហើយ តែពុំមានឯកសារគតិយុត្ត ឬកិច្ចសន្យាត្រឹមត្រូវ អភិបាលខេត្តត្រូវចាត់ចែងណែនាំឲ្យប្រជាពលរដ្ឋខ្មែរបញ្ឈប់លែងឲ្យមានការជួលដីនោះឲ្យទៅប្រជាពលរដ្ឋនៃប្រទេសជិតខាងតទៅទៀត ដោយដាក់ឱសានវាទក្នុងរយៈពេលកំណត់មួយជាក់លាក់ ស្របតាមស្ថានភាពជាក់ស្តែង។

៣- ក្នុងករណីដែលមានការជួលដីរួចហើយ តែមានឯកសារគតិយុត្ត ឬកិច្ចសន្យាត្រឹមត្រូវ ការជួលដីនោះអាចបន្តរហូតដល់អស់សុពលភាព។ បន្ទាប់ពីបញ្ចប់សុពលភាព ហាមមិនឲ្យជួលដីនោះបន្តទៅឲ្យប្រជាពលរដ្ឋនៃប្រទេសជិតខាងទៀតឡើយ។

៤-អភិបាលខេត្តត្រូវចាត់ឲ្យមានការពិនិត្យឯកសារ ឬកិច្ចសន្យាដែលប្រជាពលរដ្ឋខ្មែរបានជួលដីនៅតាមតំបន់ព្រំដែន ឲ្យទៅប្រជាពលរដ្ឋនៃប្រទេសជិតខាងនាពេលកន្លងមក ដើម្បីណែនាំឲ្យប្រជាពលរដ្ឋខ្មែរអនុវត្តតាមស្មារតីចំណុចទី២ និងចំណុចទី៣ខាងលើនេះ។

៥-ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធត្រូវដាក់ចេញនូវវិធានការ និងយុទ្ធសាស្ត្រសមស្រប ដើម្បីជួយជំរុញការបង្កបង្កើនផល និងការដាំដុះដំណាំផ្សេងៗរបស់ប្រជាពលរដ្ឋនៅតាមតំបន់ព្រំដែន ដែលជាការរួមចំណែកដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងជួយទប់ស្កាត់មិនឲ្យប្រជាពលរដ្ឋខ្មែរជួលដីឲ្យទៅប្រជាពលរដ្ឋនៃប្រទេសជិតខាង។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ដែលជាប់ព្រំដែន មន្ទីរ និងអង្គភាពជំនាញជុំវិញខេត្តដែលជាប់ព្រំដែន ត្រូវចាត់ចែងអនុវត្តឲ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់រដ្ឋបាលខេត្តជាប់ព្រំដែន
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ